# របៀបមើលគ្រោះល្អ ឬអាក្រក់ តាមក្បួនគុជសារ




+បើអស់លោកចង់មើលពីជោគជរាសីអស់លោកអ្នកទៅតាមឆ្នាំនីមួយៗ សូមមើលតាមក្បួនគុជសារខាងក្រោមនេះ :

បើប្រុស លោកឱ្យរាប់ចាប់ទីលេខ ១ រៀងរហូតដល់លេខ ៨ ហើយហួសដល់លេខ១វិញ ទាល់តែគ្រប់អាយុរបស់ខ្លួន ។

បើស្រី លោកឱ្យរាប់ពីលេខ ៨ ច្រាសទៅលេខ ៧ វិញ ទាល់តែគ្រប់អាយុរបស់ខ្លួន ហើយទំនាយមានដូចខាងក្រោម :

+បើត្រូវត្រង់លេខ១ ក្បាលគុជសារ ទំនាយថាល្អ បើគិតកិច្ចការអ្វីមួយនឹងបានសំរេចដូចយើងបំ ណង បើចេញដើរឆ្ងាយច្រើនបានលាភធំ ។

+បើត្រូវត្រង់លេខ២ ខ្នងគុជសារ ទំនាយទាយថា មានអ្នកធំជួយទំនុកបំរុងផ្គុងផ្គើម ឬត្រូវបានជួបជុំញាតិមិត្ត បងប្អូនដែលឃ្លាតគ្នាជាយូរមកហើយ ។

+បើត្រូវត្រង់លេខ៣ ចុងកន្ទុយគុជសារ ទំនាយទាយថាមិនល្អ នឹងត្រូវបាត់បង់ទ្រព្យរបស់ ឬមាន ជំងឺមកបៀតបៀនដល់រាងកាយ មានការឈ្លោះប្រកែកទាស់ទែងគ្នារវាងប្តី ប្រពន្ធក្នុងក្រុមគ្រួសារ ។

+បើត្រូវត្រង់លេខ៤ គឺជើងគុជសារខាងក្រោយ ទំនាយថាឆ្នាំនេះនឹងមានលាភ និងបានរបស់ ដែលប៉ុនប៉ងចង់បានជាយូរមកហើយ បើនឹងគិតកិច្ចការអ្វីមួយ នឹងបានសមប្រកបដូចបំណង ។

+បើត្រូវត្រង់លេខ៥ គឺត្រូវត្រង់កន្លែងលឹង្គគុជសារ ទំនាយទាយថានឹងដល់គូរព្រេង ឬមាន មនុស្សចាប់ចិត្តស្រឡាញ់ជាគូរគ្រង និងមានអ្នកផងយកលាភមកឱ្យ ។

+បើត្រូវត្រង់លេខ៦ គឺត្រូវត្រង់ជើងមុខគុជសារ ទំនាយទាយថានឹងត្រូវធ្វើដំណើរទៅទីឆ្ងាយ ឬ ត្រូវឃ្លាតចាកពីទីកន្លែងដែលធ្លាប់រស់នៅ ។

+បើត្រូវត្រង់លេខ៧ គឺប្រម៉ោយគុជសារ ទំនាយទាយថា នឹងត្រូវបានទ្រព្យរបស់មានតម្លៃ លាភសក្ការៈចូលជារឿយៗគួរជាទីពេញចិត្ត តែប្រយ័ត្នមានមនុស្សច្រណែនឈ្នានីស ។

+បើត្រូវត្រង់លេខ៨ គឺភ្លុកគុជសារ ទំនាយទាយថានឹងត្រូវបានទ្រព្យមានតម្លៃ បើមានសត្រូវប៉ុន ប៉ងប្រហារនឹងត្រូវវិនាស ។